រូបមន្តថវិកាថ្មីធ្វើឲ្យមានការផ្លាស់ប្តូរប្រសើរឡើង
ដោយលោក គ្រិស្តូហ្វ័រ ស្តាញហោហ្ស៊ែរ Christopher J. Steinhauser
អគ្គនាយកនៃសាលារៀន

យើងបានឃើញការលូតលាស់ដ៏វិជ្ជមានជាច្រើននៅសាលារៀនរបស់យើងខណៈពេលដែលយើងដាក់ប្រតិបត្តិនូវផែនការណ៏ទំនួលខុសត្រូវលើការគ្រប់គ្រងថវិកាសាលារៀន ឬហៅកាត់ថា LCAP ដែលក្រុមប្រឹក្សាភិបាលក្រសួងអប់រំយើងបានធ្វើការយល់ព្រមជាឯកច្ឆន្ទកាលពីខែមិថុនាកន្លងមកនេះ។

LCAP គឺជាការឆ្លើយតបរបស់យើងទៅនឹងការយល់ព្រមរបស់រដ្ឋទៅលើរូបមន្តគ្រប់គ្រងថវិកាសាលារៀន (LCFF) ។ រូបមន្តនេះប្រើជំនួសប្រព័ន្ធថវិកាសាលារៀនចាស់របស់រដ្ឋដែលមានភាពយ៉ាងស្មុគស្មាញ ជាមួយប្រព័ន្ធថ្មីដែលមានភាពរលូនជាងមុនហើយអនុញ្ញាតឲ្យសាលារៀនមានលទ្ធភាពច្រើនជាងមុនក្នុងការប្រើប្រាសថវិការដ្ឋយោងទៅតាមសេចក្តីចាំបាច់របស់សិស្ស។

ភ្លាមៗបន្ទាប់ពីរដ្ឋបានយល់ព្រមទៅលើរូបមន្តថ្មីនេះក្នុងឆ្នាំ២០១៣ យើងបានចាប់ផ្តើមធ្វើការប្រឹងប្រែងបញ្ចូលរួមសហគមន៏ក្នុងការបង្កើតផែនការណ៏សម្រាប់សាលារៀនយើង ដែលមានរួមទាំងការស្ទង់មតិនិងការជួបប្រជុំគ្នាផ្សេងៗ។ ផែនការណ៏នេះគឺតម្រូវឲ្យមានយោងតាមរូបមន្តថ្មីរបស់រដ្ឋ ហើយគួសបញ្ជាក់ច្បាស់ៗនូវអាទិភាពនិងវិធានការទំនួលខុសត្រូវដើម្បីបញ្ជាក់ថាធនធានត្រូវបានប្រើប្រាសឲ្យមានប្រសិទ្ធិភាព។

សព្វថ្ងៃនេះ លទ្ធផលរបស់ផែនការណ៏បានបង្ហាញនូវផលប្រយោជន៏ជាក់ស្តែងដល់សិស្សយើងទាំងអស់ ជាពិសេសដល់សិស្សដែលមានការចាំបាច់ច្រើនជាងគេ ដែលគឺជាគោលបំណងរបស់រូបមន្តថ្មីរបស់រដ្ឋ។

សិស្សសាលាវិទ្យាល័យឆ្នាំទី៣រាប់រយនាក់ទូទាំងតំបន់ឡុងប៊ីចកំពុងឆ្លៀតឱកាសទាញយកផលប្រយោជន៏នៃការរៀបបំរុងខ្លួនសំរាប់ប្រឡង SAT ដោយមិនបាច់បង់ប្រាក់ មកដល់សាលាតាំងពីព្រលឹមហើយខ្នះខ្នែងដើម្បីចូលរៀនក្នុងម៉ោងពេលព្រឹកនៅថ្ងៃសៅរ៏ នៅតាមសាលាវិទ្យាល័យធំៗនីមួយៗរបស់យើង។ ពេលដល់ចុងខែមិនា សិស្សទាំងនោះនឹងបានទទួល៣៧ម៉ោងនូវការរៀនរៀបបំរុងប្រឡង SAT ដែលមានរួមទាំងការប្រឡងសាកល្បងនិងការរៀបគ្រោងផែនការណ៏សម្រាប់ការសិក្សានៅមហាវិទ្យាល័យ។ ថ្នាក់បង្រៀនពីការរៀបបំរុងនេះជួយរៀបចំសម្រួលដល់សិស្ស ខណៈដែលមាតាបិតាសន្សំប្រាក់រាប់រយដុល្លារដែលអាចនឹងត្រូវចំណាយទៅលើថ្នាក់និងសម្ភារៈរៀបបំរុងនេះ។

ជាមួយគ្នាផងដែរ យើងបានផ្តល់ឲ្យសិស្សនូវឱកាសធំធេងដើម្បីប្រឡងថ្នាក់ក៏រិតខ្ពស់ស្មើនឹងសាលាមហាវិទ្យាល័យ AP ដោយចេញថ្លៃសឹងតែទាំងអស់ឲ្យគ្រួសារ។ ការប្រឡង AP នីមួយៗថ្លៃ $89 ប៉ុន្តែនៅឆ្នាំសិក្សានេះសិស្សបង់តែ $5 ប៉ុណ្ណុះសម្រាប់ការប្រឡងនីមួយៗហើយដោយពុំមានកំរិតចំនួនមុខវិជ្ជាឡើយ។ ចំពោះការប្រឡងនីមួយៗ សិស្សកក់ $15 ហើយនឹងបានទទួល $10 មកវិញបន្ទាប់ពីបានប្រឡងរួច។ នេះគឺមានន័យថា បើសិស្សប្រឡង AP ប្រាំមុខវិជ្ជា សិស្សបង់ថ្លៃតែ $25 ប៉ុណ្ណុះ ជាជាងបង់ $445 ។ សិស្សពីថ្នាក់ទី៨ទៅដល់ទី១២អាចចូលរួមក្នុងកម្មវិធីនេះ (សិស្សខ្លះយកថ្នាក់ AP តាំងពីថ្នាក់ទី៨ម្ល៉េះ)។

ផែនការណ៏ថវិកាសាលាយើងក៏មានចែករំលែកប្រាក់មួយចំនួនធំដើម្បីជួយដល់ក្រុមសិស្សគ្រប់ផ្នែកនៅឆ្នាំនេះក្នុងករណីជាច្រើន:

- ពង្រីកការគាំទ្រពីការអប់រំផ្តល់ឱវាទពីថ្នាក់មត្តេយ្យដល់ទី១២ $4.35 លានដុល្លារ
- ពង្រីកកម្មវិធីរៀបបំរុងសិស្សសាលាវិទ្យាល័យសម្រាប់សាលាមហាវិទ្យាល័យនិងអាជីព រួមទាំងអន្តេវាសិក $2 លានដុល្លារ
- កែឲ្យប្រសើរឡើងកម្មវិធីសិក្សាបណ្ណាល័យ $1.1 លានដុល្លារ
- កែឲ្យប្រសើរឡើងកម្មវិធីតន្ត្រីនៅសាលាបឋមសិក្សាទូទាំងក្រសួងអប់រំ $2.8 លានដុល្លារ
- កែឲ្យប្រសើរឡើងសេវាកម្មពេទ្យនៅសាលា $980,000 ដុល្លារ
- បើកឡើងវិញកម្មវិធីសិក្សានៅក្នុងរដូវក្តៅសម្រាប់សាលាវិទ្យាល័យ $1.25 លានដុល្លារ
- ធនធានសម្រាប់ការចូលរួមពីមាតាបិតា $350,000 ដុល្លារ
- កម្មវិធីគាំទ្រដល់បច្ចេកទេស $1 លានដុល្លារ

- កម្មវិធីដែលផ្តើមឡើងដោយក្រុមប្រឹក្សាភិបាលក្រសួងអប់រំ $1 លានដុល្លារ
- សន្តិសុខសាលានិងការគាំទ្រនគរបាល $2.4 លានដុល្លារ

ថែមពីនោះទៀត ផែនការណ៏ថវិកាសាលារៀននេះផ្តល់ជំនួយដល់សិស្សដែលត្រូវការជំនួយបន្ថែមៈ

- ធនធានផ្តល់ឲ្យសាលាផ្ទាល់យោងតាមស្ថានភាពប្រាក់ចំណូលតិច អ្នករៀនភាសាអង់គ្លេស និងក្មេងដែលរស់នៅជាមួយឪពុកម្តាយចិញ្ចឹម $8.8 លាន។ ប្រាក់នេះគ្រប់គ្រងដោយក្រុមប្រឹក្សាប្រចាំសាលាហើយប្រើប្រាសសម្រាប់អន្តរាគមដល់សិស្ស។ សូមមើលព័ត៏មានក្បោះក្បាយអំពីសាលារៀននីមួយៗនៅ lbschools.net ដោយចុចពាក្យ School Budgets > School Expenditure Plans
- ថ្នាក់អក្សរសាស្ត្រថ្នាក់ទី៣នៅសាលាដែលមានសិស្សក្រីក្រច្រើន អនុបាត២០:១ (សិស្ស២០គ្រូ១) $3.8 លាន
- កម្មវិធី Male/Female Academy (សម្រាប់សិស្សដែលអាចឬកំពុងមានបញ្ហាក្នុងការសិក្សា) $400,000
- ការគាំទ្រសម្រាប់អ្នករៀនភាសាអង់គ្លេសហើយនិងគ្រួសារសិស្ស $1.1 លាន
- អ្នកចាត់ចែងកម្មវិធីសម្រាប់ក្មេងដែលរស់នៅជាមួយឪពុកម្តាយចិញ្ចឹម $50,000
- គាំទ្រសម្រាប់កម្មវិធីគណិតសាស្ត្រតំបន់ឡុងប៊ីចខាងជើង $100,000

ឆ្នាំក្រោយយើងនឹងផ្តល់ការគាំទ្រដល់សិស្សកាន់តែច្រើនថែមទៀត ដែលមានរួមទាំងៈ

- បង់ថ្លៃប្រឡង PSAT សម្រាប់សិស្សពីថ្នាក់ទី៨ដល់ទី១០ទាំងអស់
- បង់ថ្លៃប្រឡង SAT សម្រាប់សិស្សថ្នាក់ទី១១ទាំងអស់
- ថ្នាក់អក្សរសាស្ត្រថ្នាក់ទី២នៅសាលាដែលមានសិស្សក្រីក្រច្រើន អនុបាត២០:១ (សិស្ស២០គ្រូ១) $4.37 លាន
- គ្រូបង្រៀនឯកទេសខាងអក្សរសាស្ត្រនៅសាលាបឋមសិក្សានិងសាលាកំរិតមធ្យមដល់ទី៨ ដែលពុំបានទទួលជំនួយថវិកា Title 1 (ជំនួយពីសហព័ន្ធ) $2.75 លាន
- ធ្វើឲ្យប្រសើរឡើងសេវាកម្មបណ្ណាល័យនៅសាលាមធ្យមសិក្សា $500,000
- ធ្វើឲ្យប្រសើរឡើងសេវាកម្មពេទ្យនៅសាលា $500,000

ផ្នែកនីមួយៗដែលឧបត្ថមដោយថវិកាសាលារៀន មានរួមទាំងវិធានការទំនួលខុសត្រូវដូចដែលតម្រូវមកពីរដ្ឋ ដូច្នេះយើងអាចសម្រេចមើលប្រសិទ្ធិភាពនៃកម្មវិធីនេះហើយនឹងធ្វើការកែតម្រូវអ្វីដែលចាំបាច់។ ទិន្នន័យក្បោះក្បាយនិងគោលដៅរបស់សាលារៀននីមួយៗមាននៅក្នុងគេហទំព័ររបស់ក្រសួងអប់រំ lbschools.net ហើយចុចលើពាក្យ LCAP > LCAP District & School Data ។ គោលដៅនេះគឺដើម្បីផ្តល់ឲ្យសិស្សនូវអនាគតភ្លឺស្វាងមួយ នៅពេលចំណាយថវិកាដែលបានមកពីអ្នកបង់ពន្ធជាឲ្យមានទំនួលខុសត្រូវនិងឲ្យបានត្រឹមត្រូវ។

អាទិភាពរបស់ផែនការណ៏ថវិកាត្រូវបានជ្រើសរើសបន្ទាប់ពីមានការពិគ្រោះពិភាក្សាជាច្រើនដងជាមួយមាតាបិតា សិស្សានុសិស្ស គ្រូបង្រៀន និងសមាជិកផ្សេងៗទៀតនៅក្នុងសហគមន៏។ ខ្ញុំជឿជាក់ថាសហគមយើងបានសម្រេចធ្វើវិនិយោគដ៏ឆ្លាតវៃ ហើយខ្ញុំរំពឹងថានឹងជំរាបដំណឹងដល់លោកអ្នកអំពីការលូតលាស់របស់យើងនៅថ្ងៃមុខជាបន្តបន្ទាប់។

សូមអរគុណដល់អស់លោកអ្នករាល់គ្នាដែលបានគាំទ្រដល់កិច្ចការដ៏សំខាន់នេះ។